## វត្ថុដែលត្រូវការពារ (protected objects)

សញ្ញាណនៃវត្ថុ ដែលត្រូវបានការពារនេះ ទាញចេញពីគោលការណ៍ច្បាប់មនុស្សធម៌អន្តរជាតិគឺ គោលការណ៍បែងចែក (principle of distinction)។ វត្ថុនេះ ខុសពីវត្ថុរបស់យោធា (military object) ក្នុងករណីមន្ទិល វត្ថុនោះនឹងត្រូវបានសន្មតថាជាវត្ថុមានលក្ខណៈស៊ីវិល (civilian object)។

វត្ថុនេះ មានមន្ទីរពេទ្យ អង្គភាពពេទ្យ និងមធ្យោបាយដឹកជញ្ជូន វត្ថុបង្ហាញនូវ emblem ដោយឡែកនៃអនុសញ្ញាហ្សឺណែវ និងពិធីសារបន្ថែមទី៣ (optional protocol III)។ វត្ថុទាំងនេះ ត្រូវបានការពារពីការវាយប្រហារ និង ការសងសឹក (reprisal)។ វត្ថុខ្លះ មិនអាចខ្វះសម្រាប់ការរស់នៅ របស់ជនស៊ីវិល។ វត្ថុខ្លះ ត្រូវការការពារជាពិសេស ដូចជាវត្ថុមានចែងក្នុងពិធីសារបន្ថែមទី២ លើអនុសញ្ញាសម្រាប់ការពារសម្បត្តិវប្បធម៌ ក្នុងពេលមានជម្លោះប្រដាប់អាវុធ (convention for the protection of cultural property in the event of armed conflict)។ ទោះបីជាយ៉ាងនេះក្តី ក៏មានករណីលើកលែង ក្នុងករណីដែលវត្ថុទាំងនោះ ផ្ទុកនូវកម្លាំងគ្រោះថ្នាក់ ដែលអាចជាកម្មវត្ថុនៃការវាយប្រហារ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 472-473)។